## មជ្ឈមណ្ឌលឯកសារកម្ពុជា

## ការអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា

## ការបង្រៀនអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)»

# វគ្គបណ្តុះបណ្តាលសាស្ត្រាចារ្យសាកលវិទ្យាល័យ

## សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា

## ថ្ងៃទី២៥-២៧ កក្កដា ឆ្នាំ២០១១



*ឯកឧត្តម អ៊ឹម សិទ្ធី និងមន្ត្រីរដ្ឋាភិបាលដទៃទៀតនឹងធ្វើជាគណៈអធិបតី ក្នុងពិធីបើកវគ្គបណ្តុះបណ្តាលនេះជាផ្លូវការនៅថ្ងៃទី២៥ ខែកក្កដា*

នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ភារកិច្ចដល់មជ្ឈមណ្ឌលឯកសារកម្ពុជារៀបចំបណ្តុះបណ្តាលសាស្ត្រាចារ្យ (ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន) នៅតាមសាកលវិទ្យាល័យ ស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ។

សេចក្តីសម្រេចនេះផុសចេញពីសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាចុះខែតុលាឆ្នាំ២០០៩ ដែលតម្រូវឲ្យនិស្សិតឆ្នាំសិក្សាមូលដ្ឋានទាំងអស់រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ អាស្រ័យហេតុនេះ ចាប់ពីថ្ងៃទី២៥ ដល់២៧ ខែកក្កដា ឆ្នាំ២០១១ មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងរៀបចំវគ្គបណ្តុះបណ្តាលសាស្ត្រាចារ្យសាកលវិទ្យាល័យជាលើកដំបូងរបស់ខ្លួនដល់សាស្ត្រាចារ្យចំនួនប្រហែល១៥០នាក់ ។ ក្នុងរយៈពេលពីរឆ្នាំទៀត មជ្ឈមណ្ឌលឯកសារកម្ពុជានឹងបណ្តុះបណ្តាលសាស្ត្រាចារ្យថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននៅតាមគ្រឹះស្ថានឧត្តមសិក្សាចំនួន៩៨ទូទាំងប្រទេស ។

ការផ្តួចផ្តើមគំនិតថ្មីនេះ ជាផ្នែកមួយនៃគម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដែលកំពុងបន្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា ដែលព្យាយាមដាក់ឲ្យអនុវត្តនូវកម្មវិធីបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅតាមវិទ្យាល័យ និងអនុវិទ្យាល័យរដ្ឋទាំងអស់ទូទាំងប្រទេសកម្ពុជា នៅត្រឹមដំណាច់ឆ្នាំ២០១៣ ។ ដើម្បីបង្រៀនប្រវត្តិសាស្ត្រដ៏ស្មុគស្មាញនិងរសើបនេះ លោកគ្រូ-អ្នកគ្រូត្រូវ

ទទួលការអប់រំជាមុនសិនទៅលើប្រវត្តិសាស្ត្រនេះ ព្រមទាំងវិធីសាស្ត្រស្តីពីថាតើត្រូវដោះស្រាយជាមួយនឹងសោកនាដកម្មយ៉ាងធំធេងនេះយ៉ាងដូចម្តេច ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា បានបណ្តុះបណ្តាលគ្រូប្រវត្តិវិទ្យានៅវិទ្យាល័យនិងអនុវិទ្យាល័យជាង១០០០នាក់រួចមកហើយ ។ នៅឆ្នាំ២០១១ មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា នឹងបណ្តុះបណ្តាលគ្រូប្រវត្តិវិទ្យាចំនួន១០០០នាក់បន្ថែមទៀត ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានចែកចាយសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យចំនួនប្រមាណ៥សែនក្បាល ដែលគោលដៅចុងក្រោយគឺការចែកសៀវភៅឲ្យបាន១លានក្បាលដល់សិស្សវិទ្យាល័យ និងអនុវិទ្យាល័យនៅទូទាំងប្រទេស ។

សេចក្តីណែនាំថ្មីរបស់រាជរដ្ឋាភិបាលកម្ពុជា នឹងគ្របដណ្តប់ទៅលើសាកលវិទ្យាល័យចំនួន៩៨ នៅក្នុងប្រទេសកម្ពុជា ព្រមទាំងនិស្សិតរាប់សែននាក់ ។ តាមរយៈការសិក្សានេះ មានការរំពឹងថានិស្សិតសាកលវិទ្យាល័យនឹងយល់ដឹងពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យតាមរយៈការវិភាគ និងវាយតម្លៃទៅលើមនោគមវិជ្ជានិងគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ វាយតម្លៃទៅលើការយល់ដឹងរបស់ជនរងគ្រោះ និងផ្លាស់ប្តូរយោបល់ជាមួយមនុស្សវ័យចំណាស់ ស្វែងរកមូលហេតុនៃអំពើប្រល័យពូជសាសន៍ ត្រួតពិនិត្យមើលពីអំពើឃោរឃៅរបស់រដ្ឋដែលនាំទៅរកការកាប់សម្លាប់ វាយតម្លៃទៅលើផលប៉ះពាល់នាពេលបច្ចុប្បន្នទៅលើសង្គមកម្ពុជាជំរុញឲ្យមានសេចក្តីករុណា ការយោគយល់គ្នានិងការផ្សះផ្សា ព្រមទាំងត្រិះរិះពិចារណាអំពីថាតើត្រូវទប់ស្កាត់អំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរនាពេលអនាគតនៅក្នុងប្រទេសកម្ពុជា និងនៅលើពិភពលោកយ៉ាងដូចម្តេច ។

សាស្ត្រាចារ្យខេត្តសជាតិនិងអន្តរជាតិ នឹងបណ្តុះបណ្តាលសាស្ត្រាចារ្យសាកលវិទ្យាល័យដោយប្រើប្រាស់សម្ភារដូចគ្នាដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឡើងសម្រាប់ការបណ្តុះបណ្តាលគ្រូវិទ្យាល័យនិងអនុវិទ្យាល័យ ។ សម្ភារបន្ថែមកម្រិតសាកលវិទ្យាល័យនឹងត្រូវបានផ្តល់ជូនដោយក្រុមអ្នកជំនាញជាតិនិងអន្តរជាតិដោយរាប់បញ្ចូលទាំងសាស្ត្រាចារ្យ ដេវីត ឆេនល័រ និងក្រុមអ្នកមានបទពិសោធន៍ក្នុងការបង្រៀន ស្តីពីការសម្លាប់រង្គាលនិងអំពើប្រល័យពូជសាសន៍នៅប្រទេសរ៉ាន់ដា ។ សម្រាប់កិច្ចខិតខំប្រឹងប្រែងលើកនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតកម្មវិធីបង្រៀនថ្មីមួយ ដែលឆ្លើយតបតាមបទដ្ឋានកម្រិតសាកលវិទ្យាល័យ ។ កម្មវិធីបង្រៀននេះត្រូវបានសរសេរដោយក្រុមអ្នកជំនាញនិងត្រួតពិនិត្យឡើងវិញដោយសាស្ត្រាចារ្យមួយក្រុមនៅក្នុងប្រទេសកម្ពុជា សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងអូស្ត្រាលី ។ កម្មវិធីបង្រៀននេះក៏ត្រូវបានយកទៅពិភាក្សាជាមួយសាស្ត្រាចារ្យសាកលវិទ្យាល័យនិងមន្ត្រីមកពីក្រសួងអប់រំ យុវជន និងកីឡា និងគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ។ ផ្តើមចេញពីវគ្គបណ្តុះបណ្តាលសាស្ត្រាចារ្យសាកលវិទ្យាល័យក្នុងខែកក្កដានេះ កម្មវិធីបង្រៀន

នេះនឹងត្រូវបានដាក់បញ្ចូលជាផ្លូវការ និងជាលើកដំបូងបង្អស់សម្រាប់សាស្ត្រាចារ្យសាកលវិទ្យាល័យមកពីទូទាំងប្រទេស ។ ដូច្នេះកម្មវិធីបង្រៀននេះអាចបញ្ជ្រាបទៅក្នុងកម្មវិធីបង្រៀន "ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥ - ១៩៧៩)" ចូលទៅក្នុងកម្មវិធីនៅតាមសាកលវិទ្យាល័យ ។

វគ្គបណ្តុះបណ្តាលនេះត្រូវបានរំពឹងថា នឹងមានគុណប្រយោជន៍ផង និងជួបបញ្ហាប្រឈមផង ដោយសារតែជារឿយៗអ្នករស់រានមានជីវិតប្រឈមមុខទៅនឹងប្រវត្តិសាស្ត្រផ្ទាល់ខ្លួន ព្រមទាំងបរិបទប្រវត្តិសាស្ត្រទាំងមូល ។ ជាទូទៅ ការផ្តល់សក្ខីកម្មផ្ទាល់ខ្លួនដោយឥតព្រាងទុកនឹងត្រូវធ្វើឡើងដោយអនុញ្ញាតឲ្យគ្រូបង្រៀនធ្វើជាសាក្សីទៅវិញទៅមក ។ ស្របពេលជាមួយគ្នានេះដែរ និស្សិតនឹងយល់ដឹងអំពីអតីតកាលរបស់ក្រុមគ្រួសារនិងសហគមន៍ ដែលជាព័ត៌មានដែលអវត្តមាននៅក្នុងសង្គមកម្ពុជាកាលពីអតីតកាល ។ និស្សិតមួយចំនួនមិនជឿថា អំពើប្រល័យពូជសាសន៍បានកើតឡើងនោះទេ ឬប្រសិនបើរឿងនោះកើតឡើង អ្នកទាំងនោះបានគិតថា រឿងនោះត្រូវបានប្រឌិតឡើងទៅវិញ ។ កញ្ញាសាត សូរិយា សិស្សម្នាក់របស់អ្នកគ្រូ ឡុង វណ្ណៈ បានជម្នះគិតពិចារណាអំពីប្រវត្តិសាស្ត្រដែលបែកខ្ញែកពីគ្នាដែលកញ្ញាបានឮពីសាច់ញាតិ ។ កញ្ញានិយាយថា "ខ្ញុំចង់ដឹងថាតើហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ប្រជាជនខ្លួនឯងច្រើនដល់ម្លឹង? ខ្ញុំចង់ដឹងថាតើហេតុអ្វីបានជាខ្មែរក្រហមទុកឲ្យប្រទេសខ្លួនឯងស្ថិតក្នុងស្ថានភាពដ៏លំបាកបែបនេះ?" ។ ការអប់រំពីអំពើប្រល័យពូជសាសន៍ស្វះស្វែងរកចម្លើយទៅនឹងសំណួរទាំងអស់នោះ និងផ្តល់នូវក្របខ័ណ្ឌមួយក្នុងការផ្គុំចំណែកប្រវត្តិសាស្ត្រយ៉ាងធំនោះចូលគ្នាវិញ ។

ទោះយ៉ាងណាក៏ដោយ វគ្គបណ្តុះបណ្តាលស្តីពីប្រវត្តិសាស្ត្រដ៏ឈឺចាប់នេះ មិនមែនជាការងាយស្រួលនោះទេ ។ ដោយសារតែការប៉ះទង្គិចផ្លូវចិត្តរបស់បុគ្គល ឬការជាប់ពាក់ព័ន្ធខាងនយោបាយ សាស្ត្រាចារ្យព្យាយាមគេចចេញពីការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហម ។ ស្រដៀងគ្នានេះដែរ និស្សិតខ្លះក៏ជម្នះទទួលស្គាល់អតីតកាល ។ ដោយសារកូនរបស់អតីតជនដៃដល់តែងតែអង្គុយនិងរស់នៅក្បែរៗគ្នាជាមួយកូនអតីតជនរងគ្រោះខ្មែរក្រហម ជម្លោះអាចផ្ទុះឡើងនៅក្នុងថ្នាក់រៀន ។

បើទោះបីជាមានបញ្ហាប្រឈមទាំងនេះក៏ដោយ ការយល់ដឹងពីប្រវត្តិសាស្ត្រជាកិច្ចការសំខាន់សម្រាប់បុគ្គលគ្រប់រូបឬសង្គមក្នុងការផ្សះផ្សាជាមួយអតីតកាលរបស់ខ្លួន ។ ឯកឧត្តម អ៊ឹម សិទ្ធី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា មានប្រសាសន៍ថា : *"ប្រជាជនកម្ពុជាជំនាន់ក្រោយត្រូវតែយល់និងដឹងអំពីអតីតកាលដ៏សោកសៅនេះដើម្បីរៀនពីអតីតកាល ទប់ស្កាត់ហេតុការណ៍បែបនេះមិនឲ្យកើតឡើងសាជាថ្មីទៀតព្រមទាំងទទួលស្គាល់និងដឹងថាតើនៅពេលណាត្រូវក្រោកឈរ ដើម្បីគោលការណ៍មនុស្សជាតិ សុចរិតភាព និងយុត្តិធម៌"* ។

ដោយហេតុនេះហើយទើបនៅថ្ងៃទី២៥ ខែកក្កដា ឯកឧត្តម អ៊ឹម សិទ្ធី និងមន្ត្រីរដ្ឋាភិបាលដទៃទៀតនឹងធ្វើជាគណៈអធិបតីក្នុងពិធីបើកវគ្គបណ្តុះបណ្តាលនេះជាផ្លូវការ ។ ក្រុមអ្នកជំនាញមកពីប្រទេសកម្ពុជា សហរដ្ឋអាមេរិក និងអូស្ត្រាលី ត្រូវបានអញ្ជើញឲ្យធ្វើបទបង្ហាញអំពីអត្ថបទនិងវិធីសាស្ត្របង្រៀនថ្មីៗ ។ សិក្ខាកាមនឹងស្តាប់ពុទ្ធសុន្ទរវិស័យប្លែកៗគ្នាទាក់ទងនឹងអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ និងអំពើប្រល័យពូជសាសន៍នៅក្នុងបរិបទសកលលោក ។

វគ្គបណ្តុះបណ្តាលសាស្ត្រាចារ្យសាកលវិទ្យាល័យ គឺជាការបោះជំហានដ៏សំខាន់ក្នុងការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទៅដល់មនុស្សជំនាន់ក្រោយ ចាប់តាំងពីបឋមសិក្សារហូតដល់កម្រិតឧត្តមសិក្សា ។ ដោយផុសចេញពីអតីតកាលដ៏រីករវររបស់ប្រទេសខ្លួន និស្សិតកម្ពុជារាប់ម៉ឺននាក់ពីមួយជំនាន់ទៅមួយជំនាន់នឹងមានឧបករណ៍ដើម្បីពង្រីកចំណេះដឹងរបស់ខ្លួនស្តីពីជម្លោះជាសកល និងជាពិសេសរួមសហការជាមួយអ្នកទាំងឡាយនៅខាងក្រៅប្រទេសកម្ពុជា ដើម្បីទប់ស្កាត់អំពើឃោរឃៅបែបនោះមិនឲ្យកើតឡើងសាជាថ្មីទៀត ។ យុវជនទាំងនេះនឹងជាភ្នាក់ងារដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍នាពេលអនាគតនិងជំរុញឲ្យមានការអត់ឱន ការអភ័យទោស និងការផ្សះផ្សា ។ វគ្គបណ្តុះបណ្តាលសាស្ត្រាចារ្យសាកលវិទ្យាល័យ ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងយូរអង្វែងដើម្បីភ្ជាប់ក្រុមយុវជនដែលជាគន្លឹះរបស់សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា ។


**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង**

លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា

ទូរស័ព្ទលេខ ០១២ ៨៦៩ ៤៥៨

លោក ឆាំង យុ

នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

ទូរស័ព្ទលេខ ០១២ ៩០៥ ៥៩៥

លោក លី សុខឃាង

អ្នកសម្របសម្រួលគម្រោង

មជ្ឈមណ្ឌលឯកសារកម្ពុជា

ទូរស័ព្ទលេខ ០១២ ៥៧០ ៤៦៥

truthlysokkheang@dccam.org




ព្រះរាជអាជ្ញារងអន្តរជាតិរបស់សាលាក្តីខ្មែរក្រហម អេនឌ្រូ ខេលី និង ឌី ខាំបូលី អ្នកនិពន្ធសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ កំពុងចែកសៀវភៅប្រវត្តិសាស្ត្រដល់សិស្សវិទ្យាល័យក្នុងស្រុកអន្លង់វែង ជាតំបន់ធ្លាប់កាន់កាប់ដោយខ្មែរក្រហម ។ សៀវភៅប្រវត្តិសាស្ត្រជាង ៥ សែនក្បាលត្រូវបានចែកចាយដល់សិស្សកម្រិតវិទ្យាល័យនិងអនុវិទ្យាល័យ ពីថ្នាក់ទី៩ ដល់ទី១២ ទូទាំងប្រទេស ។ គ្រូបង្រៀនប្រវត្តិសាស្ត្ររាប់ពាន់នាក់ទទួលបានការបណ្តុះបណ្តាល ។ ការគ្រប់គ្រងគុណភាពគ្រូបង្រៀនត្រូវបានធ្វើឡើង ប៉ុន្តែគម្រោងនេះនៅជួបឧបសគ្គខ្លះៗនៅឡើយ ។

វគ្គបណ្ដុះបណ្ដាលបានទទួលការគាំទ្រពីសំណាក់រដ្ឋាភិបាលបេលហ្សិក (Government of Belgium) ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) និងទីភ្នាក់ងារអភិវឌ្ឍអន្តរជាតិស៊ុយអែត(Sida) ។

## បញ្ជីសាកលវិទ្យាល័យ

### ក្រោមក្រសួងអប់រំ យុវជន និងកីឡា

១. សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

២. សាកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

៣. សាកលវិទ្យាល័យជាតិគ្រប់គ្រង

៤. សាកលវិទ្យាល័យជាស៊ីមកំចាយមារ

៥. សាកលវិទ្យាល័យស្វាយរៀង

៦. សាកលវិទ្យាល័យមានជ័យ

៧. សាកលវិទ្យាល័យបាត់ដំបង

៨. វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

៩. សាកលវិទ្យាល័យន័រតុន

១០. សាកលវិទ្យាល័យបៀលប្រាយ

១១. សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

១២. សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ

១៣. សាកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា

១៤. សាកលវិទ្យាល័យឯកទេសនៃកម្ពុជា

១៥. សាកលវិទ្យាល័យអន្តរជាតិ

១៦. សាកលវិទ្យាល័យមេគង្គកម្ពុជា

១៧. សាកលវិទ្យាល័យកម្ពុជា

១៨. សាកលវិទ្យាល័យវេស្ទើន

១៩. សាកលវិទ្យាល័យអាយអាយស៊ីនៃបច្ចេកវិទ្យា

២០. សាកលវិទ្យាល័យខេមរៈ

២១. សាកលវិទ្យាល័យអង្គរខេមរា
២២. សាកលវិទ្យាល័យអង្គរ
២៣. សាកលវិទ្យាល័យអាស៊ី អឺរ៉ុប
២៤. សាកលវិទ្យាល័យធនធានមនុស្ស
២៥. សាកលវិទ្យាល័យស៊ីធី
២៦. សាកលវិទ្យាល័យគ្រប់គ្រងនិងសេដ្ឋកិច្ច
២៧. សាកលវិទ្យាល័យពុទ្ធិសាស្ត្រ
២៨. សាកលវិទ្យាល័យឡាយហ្វ
២៩. សាកលវិទ្យាល័យអាស៊ីអាគ្នេយ៍
៣០. សាកលវិទ្យាល័យចេនឡា
៣១. សាកលវិទ្យាល័យលីមកុកវីង
៣២. សាកលវិទ្យាល័យខ្មែរបច្ចេកវិទ្យា និងគ្រប់គ្រង
៣៣. សាកលវិទ្យាល័យបញ្ញាជាតិ
៣៤. សាកលវិទ្យាល័យហ្សាម៉ាន់អន្តរជាតិ
៣៥. សាកលវិទ្យាល័យកម្ពុជាអន្តរជាតិ
៣៦. សាកលវិទ្យាល័យអន្តរជាតិឌូវី
៣៧. វិទ្យាស្ថានវ៉ាន់ដា
៣៨. វិទ្យាស្ថានស៊ីតិក
៣៩. វិទ្យាស្ថានប៊ែលធីអន្តរជាតិ
៤០. វិទ្យាស្ថានក្រុងអង្គរ
៤១. វិទ្យាស្ថានអភិវឌ្ឍន៍អាស៊ីសចុះ
៤២. វិទ្យាស្ថានសង្គមសាស្ត្រនិងបច្ចេកវិទ្យា
៤៣. វិទ្យាស្ថានគ្រប់គ្រងនិងអភិវឌ្ឍន៍
៤៤. វិទ្យាស្ថានអប់រំកម្ពុជា
៤៥. វិទ្យាស្ថានប្រាយហ្វូប
៤៦. វិទ្យាស្ថានអប់រំពាណិជ្ជសាស្ត្រ
៤៧. វិទ្យាស្ថានអាយស៊ីអេស

៤៨. វិទ្យាស្ថានខេមរាសាស្ត្រ
៤៩. វិទ្យាស្ថានអ៊ិនធ័រវេដ
៥០. វិទ្យាស្ថានអន្តរទ្វីបអាមេរិកកាំង
៥១. វិទ្យាស្ថានបេតអែល
៥២. វិទ្យាស្ថានសន្តប៉ូល
៥៣. វិទ្យាស្ថាន រ៉ាហ្វល អ៊ិនធើណេសិនណល ខលលីច
៥៤. វិទ្យាស្ថានហិរញ្ញវត្ថុកម្ពុជា
៥៥. វិទ្យាស្ថានខេមអេដ
៥៦. វិទ្យាស្ថានគ្រប់គ្រង ភី ស៊ី អិល
៥៧. វិទ្យាស្ថានឯកទេសសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ក្រោមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

៥៨. វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ
៥៩. វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ
៦០. មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនកម្ពុជា-ឥណ្ឌា
៦១. វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស
៦២. វិទ្យាស្ថានជាតិពហុបច្ចេកវិទ្យាកម្ពុជា
៦៣. វិទ្យាស្ថានពហុបច្ចេកទេស បាត់ដំបង
៦៤. វិទ្យាស្ថានបច្ចេកវិទ្យា បាត់ដំបង
៦៥. វិទ្យាស្ថានពហុបច្ចេកទេស កំពត
៦៦. វិទ្យាស្ថានបច្ចេកវិទ្យាឧស្សាហកម្ម
៦៧. វិទ្យាស្ថានអភិវឌ្ឍន៍សេដ្ឋកិច្ច
៦៨. មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអគ្គិសនីកម្ពុជា
៦៩. វិទ្យាស្ថានពាណិជ្ជសាស្ត្រកម្ពុជា
៧០. វិទ្យាស្ថានពាណិជ្ជសាស្ត្រនាគព័ន្ធ
៧១. វិទ្យាស្ថានខ្មែរជំនាន់ថ្មី
៧២. វិទ្យាស្ថានអនាគតយុវជនកម្ពុជា

៧៣.　វិទ្យាស្ថានសហប្រតិបត្តិការអន្តរជាតិ

៧៤.　វិទ្យាស្ថានអភិវឌ្ឍន៍និស្សិត

៧៥.　វិទ្យាស្ថានប៉ែលតុន អន្តរជាតិ

៧៦.　មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដុនបូស្កូ

## ក្រោមក្រសួងការពារជាតិ

៧៧.　សាកលវិទ្យាល័យការពារជាតិ

៧៨.　សាលានាយទាហានសកម្មគ្រាតពង

៧៩.　វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលខេមរៈភូមិន្ទ

៨០.　វិទ្យាស្ថានទព័ដើងគោក (កំពង់ស្ពឺ)

៨១.　វិទ្យាស្ថានបច្ចេកយោធា តេជោ ហ៊ុន សែន (កំពង់ស្ពឺ)

## ក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៨២.　សាកលវិទ្យាល័យភូមិន្ទកសិកម្ម

៨៣.　សាលាជាតិកសិកម្មកំពង់ចាម

៨៤.　សាលាជាតិកសិកម្មព្រែកលាប

## ក្រោមក្រសួងសុខាភិបាល

៨៥.　សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល

៨៦.　សាលាបណ្តុះបណ្តាលថែទាំវេជ្ជសាស្ត្រ

## ក្រោមក្រសួងធម្មការ និងកិច្ចការសាសនា

៨៧.　ពុទ្ធិកៈសាកលវិទ្យាល័យព្រះសីហនុរាជ

៨៨.　ពុទ្ធិកៈសាកលវិទ្យាល័យព្រះសីហនុរាជា

## ក្រោមក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

៨៩.　សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

**ក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

៩០. វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ក្រោមក្រសួងមហាផ្ទៃ**

៩១. បណ្ឌិតសភានគរបាលកម្ពុជា

**ក្រោមក្រសួងសាធារណៈការ និងដឹកជញ្ជូន**

៩២. វិទ្យាស្ថាននាវាចរណ៍កម្ពុជា

**ក្រោមទីស្តីការគណៈរដ្ឋមន្ត្រី**

៩៣. រាជបណ្ឌិតសភាកម្ពុជា

**ធនាគារជាតិនៃកម្ពុជា**

៩៤. មជ្ឈមណ្ឌលបច្ចេកទេសធនាគារ

**កំណត់សម្គាល់ ៖**

យោងតាមលោក គង់ ភូមិកា អនុប្រធាននាយកដ្ឋានឧត្តមសិក្សា សាកលវិទ្យាល័យ(១-៥៧)ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា ។ ដូច្នេះ ក្រសួងអាចអញ្ជើញសាស្ត្រាចារ្យមកចូលរួមវគ្គបណ្តុះបណ្តាលសាស្ត្រាចារ្យសាកលវិទ្យាល័យ ។ ក្នុងចំណោមសាកលវិទ្យាល័យ និងវិទ្យាស្ថានទាំង៥៧នេះ គ្រឹះស្ថានចំនួន១៥ មានទីតាំងនៅតាមបណ្តាខេត្ត និងចំនួន៤២នៅភ្នំពេញ ។ សាកលវិទ្យាល័យ (៥៨-៩៤) ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង និងស្ថាប័នផ្សេងៗ ។